ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០១១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការសម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់សាធារណជនទាំងអស់ ឱ្យបានជ្រាបថា យោងតាមការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគ្រោងនឹងសម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហៅកាត់ថា **ផ.ម.ក.** (Cambodia Securities Exchange ហៅកាត់ថា CSX) ដែលជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ នៅ**ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១** ខាងមុខនេះ និងតាមការប៉ាន់ប្រមាណអំពីវឌ្ឍនភាពនៃការងារពាក់ព័ន្ធ ការជួញដូរមូលបត្រដំបូងនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងត្រូវចាប់ផ្តើមធ្វើនៅដំណាច់ឆ្នាំ ២០១១ នេះ ។

កាលបរិច្ឆេទខុសគ្នាខាងលើនេះ គឺត្រូវបានគ្រោងឡើងស្របតាមបទពិសោធន៍នៃបណ្តាប្រទេសមួយចំនួនដែលបានកំណត់ពេលវេលានៃការចាប់ផ្តើមដំណើរការក្រុមហ៊ុនផ្សារមូលបត្រ ជាមុន ដើម្បីឲ្យទីផ្សារនេះមានពេលវេលាគ្រប់គ្រាន់ត្រៀមរៀបចំដាក់ឲ្យដំណើរការការជួញដូរមូលបត្រដំបូង។

អាស្រ័យហេតុនេះ សូមក្រុមហ៊ុនមូលបត្រ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណឬការសម្រេចទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជា ហើយមានបំណងធ្វើជាសមាជិកឬអ្នកចូលរួមនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវរួសរាន់បំពេញនីតិវិធីស្នើសុំចូលជាសមាជិកឬអ្នកចូលរួម នៅទីស្នាក់ការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (វិមានកាណាឌីយ៉ា ជាន់ទី ២៥ អគារលេខ ៣១៥ វិថីព្រះអង្គឌួង) ចាប់ពីថ្ងៃនេះតទៅ ។